# ព្រះរាជក្រម

នស/រកម/១០០៥/០២៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្តីពីការបង្ក្រាប *អំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែ* សីហា ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃ អនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃ ការធ្វើនាវាចរណ៍តាមដែនសមុទ្រ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលធ្វើនៅទីក្រុងរ៉ូម នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

នស/រកម.១០០៥.០២៦ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា
ទៀ បាញ់ ញឹក ប៊ុនឆៃ

លេខ: ៣៩៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សៅ ឆាន់

# អនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ

**រដ្ឋភាគីនានៃអនុសញ្ញានេះ**

-ដោយបានយកចិត្តទុកដាក់លើវត្ថុបំណង និង គោលការណ៍ទាំងឡាយនៃធម្មនុញ្ញសហប្រជាជាតិទាក់ទងទៅនឹងការរក្សាសន្តិភាព និង សន្តិសុខអន្តរជាតិ និងការជំរុញទំនាក់ទំនងជាមិត្តភាព និង កិច្ចសហប្រតិបត្តិការរវាងរដ្ឋនានា

-ដោយបានទទួលស្គាល់ជាពិសេសថាមនុស្សគ្រប់រូបមានសិទ្ធិខាងការរស់រានមានជីវិត មានសិទ្ធិខាងសេរីភាព និង មានសន្តិសុខផ្ទាល់ខ្លួន ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និង ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ

-ដោយមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីការកើនឡើងទូទាំងពិភពលោក នូវអំពើភេរវកម្មតាមគ្រប់រូបភាពដែលអាចបង្កគ្រោះថ្នាក់ ឬ ក៏ធ្វើអោយបាត់បង់អាយុជីវិតដល់ជនស្លូតត្រង់ ធ្វើឱ្យគ្រោះថ្នាក់ដល់សេរីភាពជាមូលដ្ឋាន និង ធ្វើឱ្យអាប់អោនយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ

-ដោយយល់ឃើញថា អំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ បង្កឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពបុគ្គលនិងទ្រព្យសម្បត្តិ ធ្វើអោយប៉ះពាល់រំខានយ៉ាងខ្លាំងដល់ប្រតិបត្តិការសេវាកម្មតាមដែនសមុទ្រ និង បន្ថយជំនឿទុកចិត្តរបស់មនុស្សនៅលើពិភពលោក ចំពោះសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ

-ដោយយល់ឃើញថា ការកើតមានឡើងនូវអំពើបែបនេះជាបញ្ហាព្រួយបារម្ភយ៉ាងខ្លាំងមួយ ដល់សហគមន៍អន្តរជាតិទាំងមូល

-ដោយជឿជាក់ចំពោះភាពចាំបាច់ជាបន្ទាន់ដើម្បីអភិវឌ្ឍកិច្ចសហប្រតិបត្តិការអន្តរជាតិមួយរវាងរដ្ឋនានា ក្នុងការបង្កើត និង អនុម័តនូវវិធានការជាក់ស្តែងនិងមានប្រសិទ្ធិភាពទាំងឡាយក្នុងការទប់ស្កាត់រាល់អំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ និង ការចោទប្រកាន់និងការដាក់ទោសដល់អ្នកប្រព្រឹត្តបទល្មើស

(ចារី)

-ដោយរំលឹកឡើងវិញនូវសេចក្ដីសំរេចលេខ ៤០/៦១ របស់មហាសន្និបាតសហប្រជាជាតិចុះថ្ងៃទី ០៩ ធ្នូ ១៩៨៥ "ដែលតាមសេចក្ដីសំរេចនេះ ស្នើដោយទទូចដល់គ្រប់រដ្ឋទាំងអស់ ដោយឯកតោភាគីក្ដី និងក្នុងកិច្ចសហប្រតិបត្តិការជាមួយបណ្ដារដ្ឋផ្សេងៗទៀតក្ដី ព្រមទាំងស្នើដល់ស្ថាប័នមានសមត្ថកិច្ចទាំងឡាយរបស់អង្គការសហប្រជាជាតិ ដើម្បីរួមចំណែកលុបបំបាត់ជាលំដាប់នូវបុព្វហេតុផ្សេងៗ ដែលជាប្រភពកំណើតនៃភេរវកម្មអន្តជាតិ និងដើម្បីប្រុងប្រយ័ត្នជាពិសេសដល់ស្ថានភាពទាំងឡាយ រួមមានអាណានិគមនិយម ជាតិសាសន៍និយម និងស្ថានភាពនានាដែលសំដែងអោយឃើញនូវការរំលោភបំពានទ្រង់ទ្រាយធំ(mass) និងជាក់ស្ដែងទៅលើសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន និងស្ថានភាពទាំងឡាយដែលជាប់ទាក់ទងនឹងការកាន់កាប់ពីបរទេស ដែលអាចបង្កអោយមានអំពើភេរវកម្មអន្តជាតិ និង អាចធ្វើអោយមានគ្រោះថ្នាក់ដល់សន្តិភាព និង សន្តិសុខអន្តរជាតិ " ។

-ដោយរំលឹកឡើងវិញបន្ថែមទៀតនូវសេចក្ដីសំរេចលេខ ៤០/៦១ ស្ដីពីការ "ថ្កោលទោសដោយឥតសង្ស័យ/ឥតព្រលាំ ថាជាឧក្រិដ្ឋជន អំពើ វិធីសាស្ត្រ និង ការអនុវត្តន៍ទាំងឡាយនៃភេរវកម្ម នៅទីកន្លែងណាក៏ដោយ និងដោយជនណាក៏ដោយ រួមបញ្ចូលទាំងអំពើទាំងឡាយដែលធ្វើអោយមានគ្រោះថ្នាក់ដល់ទំនាក់ទំនងជាមិត្តភាពរវាងរដ្ឋនានា និង សន្តិសុខរបស់ពួកគេ "។

-ដោយរំលឹកឡើងវិញផងដែរតាមសេចក្ដីសំរេចលេខ ៤០/៦១ ថា អង្គការដែនសមុទ្រអន្តរជាតិត្រូវបានកោះអញ្ជើញដើម្បី "ធ្វើការសិក្សាបញ្ហាភេរវកម្មនៅលើនាវា ឬ ប្រឆាំងនឹងនាវា ក្នុងគោលបំណងបង្កើតឡើងនូវអនុសាសន៍មួយចំនួនលើវិធានការសមស្របនានា "។

-ដោយមានការយកចិត្តទុកដាក់ ចំពោះសេចក្ដីសំរេចលេខ A.៥៨៤(១៤) ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ១៩៨៥ នៃសន្និបាតអង្គការដែនសមុទ្រអន្តរជាតិ ដែលបានអំពាវនាវ(ស្នើសុំ)អោយធ្វើការអភិវឌ្ឍវិធានការផ្សេងៗសំដៅទប់ស្កាត់រាល់អំពើខុសច្បាប់ដែលគំរាមកំហែងដល់សន្តិសុខនៃនាវា និង សុវត្ថិភាពរបស់អ្នកដំណើរ និង ក្រុមនាវិក

-ដោយកត់សំគាល់ថា អំពើទាំងឡាយរបស់ក្រុមនាវិកដែលអាស្រ័យលើវិន័យធម្មតានៅលើនាវា គឺស្ថិតនៅក្រៅការកំណត់(បទប្បញ្ញត្តិ)នៃអនុសញ្ញានេះ

-ដោយអះអាងនូវគោលបំណងនៃវិធាន និង ស្តង់ដារក្នុងការត្រួតពិនិត្យទាំងឡាយ ដែលទាក់ទងទៅនឹងការទប់ស្កាត់ និងការត្រួតពិនិត្យនៃរាល់អំពើខុសច្បាប់ប្រឆាំងនឹងនាវា និងមនុស្សនៅលើនាវា ជាមួយនឹងគោលបំណងមួយដើម្បីផ្សព្វផ្សាយទាន់ពេលវេលានូវវិធាន និងស្តង់ដារទាំងនេះទៅតាមការចាំបាច់ និង ទៅតាមខ្លឹមសារនេះ ដោយកត់សំគាល់ជាមួយការពេញចិត្តចំពោះវិធានការទាំងឡាយ សំដៅទប់ស្កាត់អំពើខុសច្បាប់ប្រឆាំងអ្នកដំណើរ

និងក្រុមនាវិកនៅលើនាវា ដូចដែលបានផ្តល់អនុសាសន៍ដោយគណៈកម្មាធិការសុវត្ថិភាពដែនសមុទ្រនៃអង្គការដែនសមុទ្រអន្តរជាតិ

- ដោយបញ្ជាក់បន្ថែមទៀតថាបញ្ហាទាំងឡាយដែលមិនត្រូវបានចែងដោយអនុសញ្ញានេះ នឹងត្រូវបន្តគ្រប់គ្រងដោយវិធាននិងគោលការណ៍ទាំងឡាយនៃនិតិអន្តរជាតិទូទៅ

-ដោយទទួលស្គាល់នូវភាពចាំបាច់សំរាប់រដ្ឋទាំងអស់ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដោយគោរពយ៉ាងតឹងរឹងតាមវិធាននិងគោលការណ៍ទាំងឡាយនៃនិតិអន្តរជាតិទូទៅ។

**បានព្រមព្រៀង** ដូចខាងក្រោមនេះ :

## មាត្រា១

វត្ថុបំណងនៃអនុសញ្ញានេះ "នាវា" មានន័យថាអាគារសមុទ្រនៃប្រភេទណាមួយក៏ដោយដែលមិនស្ថិតជាប់ជាអចិន្ត្រៃយ៍ទៅនឹងបាតសមុទ្រ រាប់បញ្ចូលទាំងនាវាដែលដើរដោយកំលាំងថាមពល នាវាមុជទឹក ឬ នាវាបណ្តែតទឹកផ្សេងៗទៀត ។

## មាត្រា២

១ អនុសញ្ញានេះមិនអនុវត្តចំពោះ :

ក- នាវាចម្បាំង ឬ

ខ- កប៉ាល់ដែលជាកម្មសិទ្ធរបស់រដ្ឋមួយ ឬដែលត្រូវបានប្រតិបត្តិដោយរដ្ឋមួយ នៅពេលដែលនាវាទាំងនោះត្រូវបានប្រើប្រាស់ជានាវាចម្បាំងជំនួយ ឬ សំរាប់គោលដៅគយ ឬនគរបាល ឬ

គ- នាវាដែលត្រូវបានដកចេញពីការធ្វើនាវាចរណ៍ ឬត្រូវបានគេលើកឡើងសំរាប់ជួសជុល ។

២ គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះប៉ះពាល់ដល់អភ័យឯកសិទ្ធិនៃនាវាចម្បាំង និង នាវាផ្សេងៗទៀតរបស់រដ្ឋដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងមិនមែនពាណិជ្ជកម្ម ។

**មាត្រា៣**

១ ជនណាម្នាក់ជាជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយ ប្រសិនបើជននោះប្រព្រឹត្តដោយខុសច្បាប់ និង ដោយចេតនា :

ក- រឹបអូស ឬ ធ្វើការត្រួតត្រាទៅលើនាវាដោយប្រើហឹង្សា ឬ ការគំរាមកំហែង ឬការបំភិតបំភ័យតាមទម្រង់ទ្រាយណាមួយ ឬ

ខ- ប្រព្រឹត្តអំពើហឹង្សាទៅលើមនុស្សនៅលើនាវា ប្រសិនបើអំពើនោះអាចធ្វើអោយមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

គ- បំផ្លាញនាវា ឬ បង្កការខូចខាតដល់នាវា ឬទំនិញរបស់នាវាដែលអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ឃ- ដាក់ ឬ ធ្វើអោយមានការដាក់នៅលើនាវា ដោយមធ្យោបាយណាក៏ដោយនូវឧបករណ៍ ឬសារធាតុដែលអាចបំផ្លិចបំផ្លាញដល់នាវានោះ ឬដែលអាចបង្កការខូចខាតដល់នាវា ឬទំនិញរបស់នាវានោះ ដែលធ្វើអោយគ្រោះថ្នាក់ ឬអាចធ្វើអោយ គ្រោះថ្នាក់ដល់សុវត្ថិភាព នៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ង- បំផ្លាញ ឬធ្វើអោយខូចខាតយ៉ាងធ្ងន់ធ្ងរដល់ឧបករណ៍សំរាប់ការធ្វើនាវាចរណ៍តាមសមុទ្រ ឬ ធ្វើអោយរំខានយ៉ាងខ្លាំងដល់ប្រតិបត្តិការរបស់នាវា ប្រសិនបើទង្វើបែបនោះអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ ឬ

ច- ផ្តល់ពត៌មានដែលខ្លួនដឹងថា "មិនពិត" ដែលជាហេតុធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា ឬ

ឆ- បង្ករបួសស្នាម ឬធ្វើឃាតជនណាម្នាក់ បើអំពើទាំងនោះ មានចំណងទាក់ទងជាមួយនឹងបទល្មើសមួយនៃបទល្មើសទាំងឡាយ ដូចមានចែងក្នុងវាក្យខ័ណ្ឌ (ក) ដល់ (ច) ដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្ត។

២ ចាត់ទុកជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយផងដែរ ប្រសិនបើជននោះ :

ក- ប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយក្នុងចំណោមបទល្មើសទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ ឬ

ខ- ជំរុញជនណាម្នាក់ផ្សេងទៀត អោយប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ១ ឬសមគំនិតជាមួយនឹងជនណាម្នាក់ដែលប្រព្រឹត្តបទល្មើសបែបណាមួយនោះ ឬ

គ- គំរាមកំហែង ដោយមាន ឬ គ្មានលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ជាតិ ក្នុងគោលបំណងបង្ខិតបង្ខំរូបវន្តបុគ្គល ឬនិតិបុគ្គលអោយធ្វើឬមិនអោយធ្វើនូវអំពើណាមួយ អោយប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខ័ណ្ឌ១ វាក្យខ័ណ្ឌ (ខ) (គ) និង (ង) ប្រសិនបើការគំរាមកំហែងនោះអាចធ្វើអោយគ្រោះថ្នាក់ដល់សុវត្ថិភាពនៃកាធ្វើនាវាចរណ៍របស់នាវានោះ ។

## មាត្រា៤

១ អនុសញ្ញានេះ ត្រូវអនុវត្ត ប្រសិនបើនាវាដែលកំពុងធ្វើនាវាចរណ៍ ឬ ដែលបានកំណត់គំរោងធ្វើដំណើរចូលទៅក្នុង ឬកាត់តាម ឬចេញពីដែនទឹកដែលស្ថិតនៅខាងក្រៅនៃសមុទ្រដែនដីនៃរដ្ឋមួយ ឬនៅខាងដែនកំណត់ម្ខាងទៀតនៃសមុទ្រដែនដីរបស់ខ្លួនដែលជាប់នឹងសមុទ្រដែនដីនៃរដ្ឋផ្សេងទៀត។

២ ក្នុងករណីដែលអនុសញ្ញានេះមិនអនុវត្តទៅតាមកថាខ័ណ្ឌ ១ ប៉ុន្តែបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះអនុវត្តប្រសិនបើជនល្មើស ឬ ជនល្មើសដោយសន្មតត្រូវបានរកឃើញនៅក្នុងទឹកដីនៃភាគីរដ្ឋមួយ ក្រៅពីរដ្ឋដែលត្រូវបានកំណត់នៅក្នុងកថាខ័ណ្ឌ១ ។

## មាត្រា៥

រដ្ឋភាគីនិមួយៗត្រូវបង្ក្រាបរាល់បទល្មើសដូចមានចែងក្នុងមាត្រា ៣ ដោយដាក់ទោសសមស្រប ដែលគិតគួរទៅដល់សភាពធ្ងន់ធ្ងរនៃបទល្មើសទាំងនោះ។

## មាត្រា ៦

១- រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការណ៍ចាំបាច់ទាំងឡាយ ដើម្បីបង្កើតនូវយុត្តាធិការរបស់ខ្លួនលើបទល្មើសនានាដូចមានចែងក្នុងមាត្រា៣ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តៈ

ក-ប្រឆាំងទៅនឹង ឬ នៅលើនាវាដែលមានដាក់ទង់ជាតិនៃរដ្ឋនោះ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ឬ

ខ- នៅក្នុងទឹកដីនៃរដ្ឋនោះ រួមបញ្ចូលទាំងនៅក្នុងសមុទ្រដែនដីនៃរដ្ឋនោះ ឬ

គ- ដោយជនជាតិណាម្នាក់នៃរដ្ឋនោះ

២- រដ្ឋភាគីមួយអាចបង្កើតផងដែរនូវយុត្តាធិការរបស់ខ្លួន លើបទល្មើសបែបណាមួយនោះ នៅពេលដែលៈ

ក- បទល្មើសនោះ ត្រូវបានប្រព្រឹត្តដោយនិរេតិកជន (ជនដែលគ្មានសញ្ជាតិ) ដែលមាននិវេសនដ្ឋានជាទំលាប់របស់ខ្លួននៅក្នុងរដ្ឋនោះ ឬ

ខ- ក្នុងកំឡុងពេលនៃការប្រព្រឹត្តបទល្មើសនោះ ជនជាតិណាម្នាក់នៃរដ្ឋនោះត្រូវបានឃាត់ខ្លួន ត្រូវបានគំរាមកំហែង ត្រូវបានធ្វើអោយរងរបួស ឬ ត្រូវបានសំលាប់ ឬ

គ- បទល្មើសនោះត្រូវបានប្រព្រឹត្តក្នុងបំណងបង្ខិតបង្ខំរដ្ឋនោះអោយធ្វើ ឬ មិនអោយធ្វើនូវអំពើណាមួយ។

៣- រដ្ឋភាគីនីមួយៗដែលបានបង្កើតយុត្តាធិការលើករណីទាំងឡាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ ត្រូវជូនដំណឹងដល់អគ្គលេខាធិការនៃអង្គការដែនសមុទ្រអន្តរជាតិ (បន្ទាប់ពីនេះហៅថា "អគ្គលេខាធិការ ")។ បន្ទាប់មកប្រសិនបើរដ្ឋភាគីនោះលុបចោលនូវយុត្តាធិការនេះ រដ្ឋភាគីនោះត្រូវជូនដំណឹងដល់អគ្គលេខាធិការ។

៤- រដ្ឋភាគីនិមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្កើតនូវយុត្តាធិការរបស់ខ្លួនលើបទល្មើសនានា ដូចមានចែងក្នុងមាត្រា៣ ក្នុងករណីទាំងឡាយដែលជនល្មើសដោយសន្មតមានវត្តមាននៅក្នុងទឹកដីនៃរដ្ឋនោះ ហើយរដ្ឋនោះមិនធ្វើបត្យាប័នជនល្មើសនោះទៅអោយរដ្ឋភាគីណាមួយផ្សេងទៀតដែលបានបង្កើតយុត្តាធិការ ដោយអនុលោមតាមកថាខ័ណ្ឌ១ និង២ នៃមាត្រានេះ។

៥- អនុសញ្ញានេះ រាប់បញ្ចូលទាំងយុត្តាធិការព្រហ្មទណ្ឌដែលត្រូវបានអនុវត្តស្របទៅតាមច្បាប់ជាតិ។

## មាត្រា៧

១- ប្រសិនបើស្ថានភាពនានាត្រឹមត្រូវនិងស្របទៅតាមច្បាប់ជាតិរបស់ខ្លួនហើយនោះ រដ្ឋភាគីនីមួយៗដែលជនល្មើស ឬ ជនល្មើសដោយសន្មតស្ថិតនៅ ត្រូវឃុំខ្លួនជនល្មើសនោះ ឬ ត្រូវចាត់វិធានការចាំបាច់ផ្សេងទៀត ដើម្បីធានាវត្តមានរបស់ជនល្មើសនោះ សំរាប់រយៈពេលមួយចាំបាច់ដើម្បីដំណើរការកាត់ទោស ឬ ដំណើរការនិតិវិធីនៃការធ្វើបត្យាប័ន។

២- រដ្ឋនោះត្រូវធ្វើការស៊ើបអង្កេតបឋមមួយជាបន្ទាន់ ទៅលើហេតុការណ៍ទាំងឡាយ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន ។

៣- ជនណាម្នាក់ដែលត្រូវបានគេចាត់វិធានការនានា ដូចមានចែងនៅក្នុងកថាខ័ណ្ឌ១ ជននោះត្រូវបានផ្តល់សិទ្ធិ ដើម្បី :

ក- ទាក់ទងជាបន្ទាន់ជាមួយអ្នកតំណាងត្រឹមត្រូវដែលស្ថិតនៅជិតបំផុតនៃរដ្ឋដែលខ្លួនមានសញ្ជាតិ ឬរដ្ឋដែលខ្លួនមានសិទ្ធិបង្កើតទំនាក់ទំនងនោះ ឬប្រសិនបើខ្លួនជានិរបេតិកជន (ជនគ្មានសញ្ជាតិ) ត្រូវទាក់ទងជាមួយរដ្ឋដែលខ្លួនមាននិវេសនដ្ឋានជាទំលាប់នៅក្នុងរដ្ឋនោះ ។

ខ- ទទួលបាននូវការសួរសុខទុក្ខដោយអ្នកតំណាងនៃរដ្ឋនោះ ។

៤- សិទ្ធិទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌ ៣ ត្រូវបានអនុវត្តក្នុងក្របខ័ណ្ឌនៃច្បាប់និងបទបញ្ជាទាំងឡាយ នៃរដ្ឋដែលជនល្មើស ឬ ជនល្មើសដោយសន្មតស្ថិតនៅ ដោយអាស្រ័យលើលក្ខខណ្ឌថាច្បាប់ និង បទបញ្ជាទាំងនោះ ត្រូវធ្វើអោយបានសំរេចពេញលេញនូវគោលបំណង ដែលសិទ្ធិទាំងឡាយត្រូវបានព្រមព្រាងសំរាប់គោលបំណងទាំងនោះ ដូចមានចែងក្នុងកថាខ័ណ្ឌ៣ ។

៥- នៅពេលណាដែលរដ្ឋភាគីមួយបានឃុំខ្លួនជនណាម្នាក់ ដោយអនុលោមតាមមាត្រានេះ រដ្ឋភាគីនោះត្រូវជូនដំណឹងជាបន្ទាន់ដល់រដ្ឋនានាដែលបានបង្កើតយុត្តាធិការស្របតាមមាត្រា ៦ កថាខ័ណ្ឌ១ និង ប្រសិនបើរដ្ឋភាគីនោះគិតថាគួរធ្វើ ត្រូវជូនដំណឹងដល់រដ្ឋដែលចាប់អារម្មណ៍នានាអំពីហេតុការណ៍ដែលជននោះកំពុងឃុំខ្លួន និង អំពីស្ថានភាពនានាដែលនាំទៅដល់ការចេញដីការឃុំខ្លួននោះ ។ រដ្ឋដែលធ្វើការអង្កេតជាបឋម ដូចមានចែងក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ត្រូវរាយការណ៍ជាប្រញាប់នូវលទ្ធផលទៅរដ្ឋដែលពោលខាងលើ ហើយត្រូវបញ្ជាក់ថាតើរដ្ឋខ្លួនមានបំណងអនុវត្តយុត្តាធិការ ឬអត់ ។

## មាត្រា៨

១- ប្រធាននាវានៃរដ្ឋភាគី (The flag State រដ្ឋម្ចាស់ទង់ជាតិ) អាចប្រគល់អោយអាជ្ញាធរនៃរដ្ឋភាគីផ្សេងណាមួយទៀត(The receiving State)(រដ្ឋទទួល) នូវជនណាម្នាក់ដែលមានមូលហេតុគ្រប់គ្រាន់ ដែលជឿថាជននោះបានប្រព្រឹត្តបទល្មើសមួយក្នុងចំណោមបទល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា ៣ ។

២- រដ្ឋម្ចាស់ទង់ជាតិត្រូវធានាថា ប្រធាននាវារបស់ខ្លួនមានកាតព្វកិច្ចជូនដំណឹងទៅអាជ្ញាធរទាំងឡាយនៃរដ្ឋទទួលអំពីបំណងរបស់ខ្លួនដើម្បីប្រគល់ជនណាម្នាក់ និងមូលហេតុផ្សេងៗទៀតដែលបង្ហាញអំពីសេចក្តីសំរេចនេះ នៅពេល

ណាដែលអាចធ្វើទៅបាននិងបើអាច មុនពេលចូលទៅក្នុងសមុទ្រដែនដីនៃរដ្ឋទទួល ដោយមាននាំជននោះដែលប្រធាន នាវាមានបំណងយកមកប្រគល់ ដោយអនុលោមតាមកថាខ័ណ្ឌ ១។

៣- រដ្ឋទទួលព្រមទទួលនូវការប្រគល់ខ្លួននោះ លើកលែងតែករណីរដ្ឋនោះមានមូលហេតុដែលអាចចាត់ទុកថា អនុសញ្ញានេះមិនអាចអនុវត្តបានចំពោះអំពើនានាដែលបណ្តាលអោយមានការបញ្ជូនខ្លួន និងត្រូវចាត់និតិវិធី ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៧ ។ រាល់ការបដិសេធទទួលខ្លួនជនណាម្នាក់ត្រូវបង្ហាញពីមូលហេតុនៃការបដិសេធនោះ។

៤- រដ្ឋម្ចាស់ទង់ជាតិត្រូវធានាថាប្រធាននាវារបស់ខ្លួនមានកាតព្វកិច្ចផ្តល់អោយអាជ្ញាធរនានានៃរដ្ឋទទួលនូវ ភស្តុតាងដែលទាក់ទងទៅនឹងបទល្មើសដោយសន្មត។

៥- រដ្ឋទទួលដែលបានទទួលយកការប្រគល់ខ្លួនជនណាម្នាក់ ស្របតាមកថាខ័ណ្ឌ ៣ អាចធ្វើការស្នើសុំរដ្ឋម្ចាស់ទង់ជាតិអោយព្រមទទួលយកជននោះវិញ ។ រដ្ឋម្ចាស់ទង់ជាតិត្រូវពិចារណាសំណើរបែបណាមួយ ហើយប្រសិនបើយល់ព្រមទៅតាមសំណើរនោះ ត្រូវធ្វើតាមនិតិវិធី ស្របតាមមាត្រា ៧ ។ ប្រសិនបើ រដ្ឋម្ចាស់ទង់ជាតិបដិសេធចោលសំណើរមួយ រដ្ឋនោះត្រូវបង្ហាញពីមូលហេតុអំពីសេចក្តីសំរេចនោះដល់រដ្ឋទទួល។

## មាត្រា៩

គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះប៉ះពាល់តាមរបៀបណាមួយទៅលើវិធាននៃនិតិអន្តរជាតិ ដែលទាក់ទងទៅនឹងការប្រតិបត្តិសមត្ថកិច្ចនៃរដ្ឋទាំងឡាយក្នុងរឿងស៊ើបអង្កេត ឬការពង្រឹងសមត្ថកិច្ចនៅលើនាវាទាំងឡាយដែលមិនដាក់ទង់ជាតិរបស់ខ្លួន។

## មាត្រា១០

១- ក្នុងករណីដែលមាត្រា៦ត្រូវអនុវត្ត រដ្ឋភាគីដែលជនល្មើស ឬជនល្មើសដោយសន្មតត្រូវបានរកឃើញនៅក្នុងទឹកដីរបស់ខ្លួន ប្រសិនបើរដ្ឋភាគីនោះមិនធ្វើបត្យាប័នជនល្មើសទេ ខ្លួនត្រូវមានកាតព្វកិច្ចដាក់ជូនករណីនេះ ដោយគ្មានការយឺតយ៉ាវនិងគ្មានករណីលើកលែងណាមួយ ទៅអោយអាជ្ញាធរមានសមត្ថកិច្ចទាំងឡាយរបស់ខ្លួនពិនិត្យដើម្បីកាត់

ទោសតាមនិតិវិធី ស្របតាមច្បាប់នៃរដ្ឋនោះ ទោះបីបទល្មើសត្រូវបានឬមិនត្រូវបានប្រព្រឹត្តនៅលើទឹកដីរបស់ខ្លួនក៏ដោយ។ អាជ្ញាធរទាំងនោះត្រូវធ្វើការសំរេចក្នុងលក្ខណៈដូចគ្នា ចំពោះករណីបទល្មើសណាមួយផ្សេងទៀតដែលមានលក្ខណៈធ្ងន់ធ្ងរ ស្របទៅនឹងច្បាប់របស់រដ្ឋនោះ។

២- ជនណាម្នាក់ដែលនិតិវិធីត្រូវអនុវត្តចំពោះខ្លួន ទាក់ទងទៅនឹងបទល្មើសណាមួយក្នុងចំណោមបទល្មើស ទាំងឡាយដូចមានចែងក្នុងមាត្រា៣ ត្រូវបានធានានូវប្រព្រឹត្តកម្មត្រឹមត្រូវ គ្រប់ដំណាក់កាលនៃនិតិវិធី រួមទាំងទទួលបាននូវសិទ្ធិ និង ការធានាទាំងឡាយដូចមានចែងដោយច្បាប់រដ្ឋដែលជននោះស្ថិតនៅ។

## មាត្រា១១

១- បទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា៣ ត្រូវចាត់ទុកដោយរាប់បញ្ចូលជាបទល្មើសដែលធ្វើបត្យាប័នបាននៅក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលមានរវាងរដ្ឋភាគី។ រដ្ឋភាគីទាំងឡាយត្រូវប្រកាន់យកដោយរាប់បញ្ចូលបទល្មើសទាំងនោះជាបទល្មើសដែលធ្វើបត្យាប័នបាននៅក្នុងរាល់សន្ធិសញ្ញាបត្យាប័នដែលនឹងត្រូវបង្កើតឡើងរវាងរដ្ឋភាគីទាំងនោះ។

២- ប្រសិនបើរដ្ឋភាគីមួយដែលធ្វើបត្យាប័នក្នុងលក្ខខណ្ឌមានសន្ធិសញ្ញា ទទួលសំណើរធ្វើបត្យាប័នពីរដ្ឋភាគីមួយផ្សេងទៀតដែលមិនមានសន្ធិសញ្ញាបត្យាប័ន រដ្ឋភាគីដែលត្រូវបានស្នើសុំ តាមជំរើសរបស់ខ្លួន អាចចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សំរាប់ការធ្វើបត្យាប័ន ពាក់ព័ន្ធទៅនឹងបទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា៣ ។ ការធ្វើបត្យាប័នត្រូវស្ថិតនៅក្រោមលក្ខខណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់របស់រដ្ឋភាគីដែលត្រូវបានស្នើសុំ។

៣- រដ្ឋភាគីទាំងឡាយដែលមិនដាក់បត្យាប័ននៅក្រោមលក្ខខណ្ឌដែលមានសន្ធិសញ្ញា ត្រូវទទួលស្គាល់បទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា៣ជាបទល្មើសដែលធ្វើបត្យាប័នបានរវាងរដ្ឋទាំងនោះ ក្រោមលក្ខខណ្ឌផ្សេងៗដូចមានចែងក្នុងច្បាប់របស់រដ្ឋភាគីដែលត្រូវបានស្នើសុំ ។

៤- ប្រសិនបើចាំបាច់ ក្នុងបំណងធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសទាំងឡាយដូចមានចែងក្នុងមាត្រា ៣ ត្រូវបានចាត់ទុកមិនត្រឹមតែជាបទល្មើសដែលបានកើតឡើងនៅទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទេ ថែមទាំងត្រូវបានចាត់ទុកដូចជាបទល្មើសទាំងនោះបានកើតឡើងក្នុងទីកន្លែងដែលឋិតនៅក្រោមសមត្ថកិច្ចនៃរដ្ឋភាគីដែលបានស្នើសុំបត្យាប័នផងដែរ ។

៥- រដ្ឋភាគីមួយដែលទទួលសំណើរសំរាប់ធ្វើបត្យាប័នលើសពី ១ ពីបណ្តារដ្ឋដែលបានបង្កើតសមត្ថកិច្ចរបស់ខ្លួន ដោយអនុលោមតាមមាត្រា ៦ និងដែលសំរេចមិនធ្វើការកាត់ទោស កាលបើខ្លួនជ្រើសរើសរដ្ឋដើម្បីធ្វើបត្យាប័នជន ល្មើស ឬជនល្មើសដោយសន្មតនោះ ត្រូវគិតគូរទៅដល់ផលប្រយោជន៍ និង ការទទួលខុសត្រូវនៃរដ្ឋភាគីដែលបទ ល្មើសបានកើតមានឡើងនៅលើនាវាដែលដាក់ទង់ជាតិនៃរដ្ឋភាគីនោះ ។

៦- ដោយអនុលោមតាមអនុសញ្ញានេះ ក្នុងការពិចារណាសំណើរសំរាប់ធ្វើបត្យាប័ននៃជនល្មើសដោយសន្មត រដ្ឋ ដែលត្រូវបានស្នើសុំត្រូវគិតគូទៅដល់បញ្ហាដែលថាតើសិទ្ធិរបស់ជនល្មើសដោយសន្មតដូចមានចែងក្នុងមាត្រា ៧ កថា ខ័ណ្ឌ ៣ អាចអនុវត្តបានដែរឬទេ នៅក្នុងរដ្ឋដែលស្នើសុំ ។

៧- ដោយទាក់ទងទៅនឹងបទល្មើសទាំងឡាយដូចបានកំណត់ច្បាស់នៅក្នុងអនុសញ្ញានេះ បទប្បញ្ញត្តិទាំងឡាយ នៃសន្ធិសញ្ញានិងកិច្ចព្រមព្រាងបត្យាប័នដែលត្រូវបានបង្កើតឡើងរវាងរដ្ឋភាគី ត្រូវកែប្រែរវាងរដ្ឋភាគី ក្នុងលក្ខ ខណ្ឌដែលបទប្បញ្ញត្តិទាំងនោះវិសមិតជាមួយអនុសញ្ញានេះ ។

**មាត្រា១២**

១- រដ្ឋភាគីទាំងឡាយត្រូវផ្តល់អោយគ្នានូវវិធានការនៃការជួយគ្នាទៅវិញទៅមកផ្នែកយុត្តាធិការ អោយទូលំ ទូលាយ ក្នុងរាល់នីតិវិធីព្រហ្មទណ្ឌដែលទាក់ទងនឹងបទល្មើសដែលមានចែងក្នុងមាត្រា៣ ដោយរួមមានទាំងការជួយ អោយទទួលបាននូវភស្តុតាងចាំបាច់ទាំងឡាយដែលពួកគេអាចប្រើប្រាស់បានសំរាប់នីតិវិធី ។

២- រដ្ឋភាគីទាំងឡាយត្រូវអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនទៅតាមកថាខ័ណ្ឌ ១ ស្របជាមួយនឹងសន្ធិសញ្ញាណាមួយ ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកយុត្តាធិការដែលអាចមានរវាងគ្នា។ ក្នុងករណីដែលគ្មានសន្ធិសញ្ញាបែបនេះទេ រដ្ឋ ភាគីត្រូវផ្តល់នូវការជួយគ្នាទៅវិញទៅមកនូវផ្នែកយុត្តាធិការនេះ ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ពួកគេ ។

**មាត្រា១៣**

១- រដ្ឋភាគីត្រូវធ្វើសហប្រតិបត្តិការ ក្នុងការទប់ស្កាត់បទល្មើសដូចមានចែងក្នុងមាត្រា ៣ ជាអាទិ៍ :

ក- ចាត់រាល់វិធានការដែលអាចអនុវត្តបានដើម្បីទប់ស្កាត់រាល់ការរៀបចំនៅក្នុងទឹកដីរៀង១ខ្លួន ក្នុងគោល បំណងប្រព្រឹត្តបទល្មើសទាំងឡាយនៅខាងក្នុង ឬ នៅខាងក្រៅទឹកដីរបស់ខ្លួន ។

ខ- ផ្លាស់ប្តូរពត៌មានដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួន និងសំរបសំរួលវិធានការផ្នែករដ្ឋបាល និង វិធានការផ្សេងៗដែលសមស្រប ដើម្បីទប់ស្កាត់រាល់ការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៣ ។

២- នៅពេលដែលការធ្វើដំណើរឆ្លងកាត់របស់នាវាមួយត្រូវបានពន្យា ឬបង្អាក់ ដោយសារតែការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣ រដ្ឋភាគីដែលនាវា ឬអ្នកដំណើរ ឬក្រុមនាវិកស្ថិតនៅក្នុងទឹកដីរបស់ខ្លួន ត្រូវប្រឹងប្រែងតាមដែលអាចធ្វើទៅបាន ដើម្បីជៀសវាងនូវការឃាត់ទុក ឬពន្យាដំណើរចំពោះនាវា អ្នកដំណើរ ក្រុមនាវិក ឬទំនិញដោយមិនត្រឹមត្រូវ ។

### មាត្រា១៤

រដ្ឋភាគីណាមួយដែលមានហេតុផលអាចជឿបានថាបទល្មើសមួយដូចមានចែងក្នុងមាត្រា ៣ នឹងត្រូវបានប្រព្រឹត្តឡើង ដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួន ត្រូវផ្តល់ជាបន្ទាន់តាមដែលអាចធ្វើទៅបាននូវពត៌មានពាក់ព័ន្ធដែលខ្លួនមាន ទៅអោយរដ្ឋទាំងឡាយដែលខ្លួនជឿថារដ្ឋទាំងនោះបានបង្កើតសមត្ថកិច្ចរបស់ខ្លួនស្របតាមមាត្រា ៦ ។

### មាត្រា១៥

១- ដោយអនុលោមទៅតាមច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីនិមួយៗត្រូវផ្តល់ជូនអគ្គលេខាធិការអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននូវពត៌មានដែលពាក់ព័ន្ធណាមួយដែលខ្លួនមាន ទាក់ទងទៅនឹង :

ក- ស្ថានភាពទាំងឡាយនៃបទល្មើស

ខ- វិធានការដែលត្រូវបានចាត់ឡើងដោយអនុលោមតាមមាត្រា១៣ កថាខ័ណ្ឌ២

គ- វិធានការដែលត្រូវបានចាត់ឡើងដែលទាក់ទងទៅនឹងជនល្មើស ឬជនល្មើសដោយសន្មត និង ជាពិសេសរាល់លទ្ធផលនៃនីតិវិធីនៃការធ្វើបត្យាប័នណាមួយ ឬនីតិវិធីផ្នែកយុត្តិធិការផ្សេងទៀត ។

២- ដោយអនុលោមតាមច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីដែលបានកាត់ទោសជនល្មើសដោយសន្មត ត្រូវជូនដំណឹងពីលទ្ធផលស្ថាពរនៃនីតិវិធីទាំងនោះទៅអគ្គលេខាធិការ ។

៣- រាល់ពត៌មានទាំងឡាយដែលបានទទួលស្របតាមកថាខ័ណ្ឌ១ និង ២ ត្រូវបានផ្សព្វផ្សាយដោយអគ្គលេខាធិការទៅគ្រប់រដ្ឋភាគី ទៅសមាជិកទាំងឡាយនៃអង្គការដែនសមុទ្រអន្តរជាតិ (បន្ទាប់ពីនេះហៅថា"អង្គការ" ) ទៅរដ្ឋផ្សេងៗដែលជាប់ពាក់ព័ន្ធ និងទៅអង្គការអន្តររដ្ឋាភិបាលអន្តរជាតិដែលសមស្រប ។

## មាត្រា១៦

១- រាល់ជម្លោះរវាងរដ្ឋភាគី ២ ឬច្រើន ពាក់ព័ន្ធក្នុងការបកស្រាយឬការអនុវត្តន៍នៃអនុសញ្ញានេះ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចាក្នុងពេលដ៏សមស្របមួយ ត្រូវដាក់ជូនទៅមជ្ឈត្តវិនិច្ឆ័យទៅតាមសំណើរនៃរដ្ឋភាគីណាមួយ។ ប្រសិនបើក្នុងរយៈពេល ៦ខែ ចាប់ពីថ្ងៃនៃការដាក់សំណើរសំរាប់មជ្ឈត្តវិនិច្ឆ័យ ភាគីទាំងនោះនៅតែមិនអាចឈានទៅដល់ការព្រមព្រៀងលើការរៀបចំមជ្ឈត្តវិនិច្ឆ័យបានទេនោះ ភាគីណាមួយនៃភាគីទាំងនោះអាចដាក់ជំលោះនេះជូនទៅតុលាការយុត្តិធម៌អន្តរជាតិ ដោយដាក់បណ្តឹងអនុលោមទៅតាមលក្ខន្តិកៈ របស់តុលាការ ។

២- នៅពេលចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការយល់ព្រមលើអនុសញ្ញានេះ ឬការសុំចូលជាសមាជិក រដ្ឋនិមួយៗអាចប្រកាសថា ខ្លួនមិនចាត់ទុកថាត្រូវបានចងភ្ជាប់ដោយបទប្បញ្ញត្តិណាមួយ ឬដោយរាល់បទប្បញ្ញត្តិនៃកថាខ័ណ្ឌ ១ ទេ។ រដ្ឋភាគីផ្សេងទៀតមិនត្រូវបានចងភ្ជាប់ដោយបទប្បញ្ញត្តិទាំងនោះ ប្រសិនបើមានរដ្ឋភាគីណាមួយ បានដាក់លក្ខខណ្ឌបន្ថែមបែបនេះមួយ។

៣- រដ្ឋណាមួយដែលបានដាក់លក្ខខណ្ឌបន្ថែម អនុលោមតាមកថាខ័ណ្ឌ ២ អាចដកលក្ខខណ្ឌនោះវិញបាន នៅគ្រប់ពេល ដោយជូនដំណឹងទៅអគ្គលេខាធិការ ។

## មាត្រា១៧

១- អនុសញ្ញានេះ ត្រូវបានបើកចំហ នៅទីក្រុងរ៉ូមនាថ្ងៃទី ១០ ខែមិនា ឆ្នាំ ១៩៨៨ សំរាប់ការចុះហត្ថលេខារបស់រដ្ឋទាំងឡាយដែលបានចូលរួមក្នុងសន្និសីទអន្តរជាតិស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ និង ការចុះហត្ថលេខាសំរាប់រដ្ឋទាំងអស់ នៅទីស្នាក់ការនៃអង្គការ ចាប់ពីថ្ងៃទី១៤ ខែ មិនា ឆ្នាំ ១៩៨៨ រហូតដល់ថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៨៩។ បន្ទាប់មក អនុសញ្ញានេះនៅតែបើកចំហសំរាប់ការចូលជាសមាជិក។

២- រដ្ឋនានាអាចបញ្ជាក់ពីការយល់ព្រមរបស់ខ្លួនក្នុងការគោរពតាមអនុសញ្ញានេះបាន ដោយ ៖

ក- ការចុះហត្ថលេខាដោយគ្មានលក្ខខណ្ឌផ្ដល់សច្ចាប័ន ការព្រមទទួលយក ឬការយល់ព្រម ឬ

ខ- ការចុះហត្ថលេខាដោយឋិតក្រោមលក្ខខណ្ឌសច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រមដែលតំរូវផ្ដល់សច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រម ឬ

គ- ការចូលជាសមាជិក ។

៣- ការផ្ដល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក មានប្រសិទ្ធិភាព ដោយការដាក់ជូននូវលិខិតុបករណ៍មួយទៅអគ្គលេខាធិការ ។

## មាត្រា១៨

១- អនុសញ្ញានេះចូលជាធរមាននៅ ៩០ ថ្ងៃ បន្ទាប់ពីរដ្ឋចំនួន ១៥ បានចុះហត្ថលេខាលើអនុសញ្ញានេះ ដោយគ្មានលក្ខខណ្ឌផ្ដល់សច្ចាប័ន ការព្រមទទួលយក ឬ ការយល់ព្រម ឬបានដាក់លិខិតុបករណ៍សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក ។

២- ចំពោះរដ្ឋមួយដែលដាក់លិខិតុបករណ៍សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិកនៃអនុសញ្ញានេះ បន្ទាប់ពីលក្ខខណ្ឌនានាសំរាប់ចូលជាធរមានត្រូវបានបំពេញរួចហើយនោះ សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬ ការចូលជាសមាជិក ចាប់មានសុពលភាព ៩០ ថ្ងៃ បន្ទាប់ពីថ្ងៃនៃការដាក់លិខិតុបករណ៍ ។

## មាត្រា១៩

១- អនុសញ្ញានេះ អាចត្រូវបានប្រកាសមិនយល់ព្រមដោយរដ្ឋភាគីណាមួយ នៅពេលណាក៏បាន បន្ទាប់ពីផុតកំណត់រយៈពេល១ឆ្នាំ ចាប់ពីថ្ងៃដែលអនុសញ្ញានេះចូលជាធរមានសំរាប់រដ្ឋនោះ ។

២- ការប្រកាសមិនយល់ព្រម អាចមានសុពលភាពបាន ដោយការដាក់លិខិតុបករណ៍នៃការប្រកាសមិនយល់ព្រមនោះ ជូនទៅអគ្គលេខាធិការ ។

៣- សេចក្តីប្រកាសមិនយល់ព្រម ចាប់មានសុពលភាពរយៈពេល ១ឆ្នាំ ឬក៏រយៈពេលយូរជាងនេះដូចដែលបានបញ្ជាក់នៅក្នុងលិខិតុបករណ៍នៃសេចក្តីប្រកាសមិនយល់ព្រម បន្ទាប់ពីការទទួលលិខិតុបករណ៍នៃសេចក្តីប្រកាសមិនយល់ព្រមនេះ ដោយអគ្គលេខាធិការ ។

## មាត្រា២០

១- សន្និសិទមួយអាចត្រូវបានកោះប្រជុំ ដោយ"អង្គការ" សំរាប់គោលបំណងពិនិត្យឡើងវិញ ឬ វិសោធនកម្មលើអនុសញ្ញានេះ ។

២- អគ្គលេខាធិការ អាចកោះប្រជុំរដ្ឋភាគីទាំងឡាយនៃអនុសញ្ញានេះ ដើម្បីធ្វើសន្និសិទពិនិត្យឡើងវិញ ឬ វិសោធនកម្មអនុសញ្ញានេះ ទៅតាមសំណើរចំនួន ១ភាគ៣នៃរដ្ឋភាគី ឬ រដ្ឋភាគីចំនួន ១០ ប្រសិនបើតួលេខខាងក្រោយនេះខ្ពស់ជាង ។

៣- លិខិតុបករណ៍ណាមួយនៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬការចូលជាសមាជិក ដែលត្រូវបានដាក់ជូន បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃវិសោធនកម្មលើអនុសញ្ញានេះ ត្រូវបានចាត់ទុកថាអនុវត្តតាមអនុសញ្ញាដែលបានធ្វើវិសោធនកម្មរួច ។

## មាត្រា២១

១- អនុសញ្ញានេះត្រូវបានតំកល់ទុកនៅអគ្គលេខាធិការ ។

២- អគ្គលេខាធិការត្រូវ :

ក- ផ្តល់ពត៌មានដល់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ឬ បានចូលជាសមាជិកនៃអនុសញ្ញានេះ ព្រមទាំងសមាជិកទាំងអស់នៃអង្គការនេះអោយបានដឹងអំពី :

(១)- ហត្ថលេខាថ្មីនិមួយៗ ឬការដាក់លិខិតុបករណ៍ថ្មីនៃសច្ចាប័ន ការព្រមទទួលយក ការយល់ព្រម ឬការចូលជាសមាជិក ព្រមទាំងកាលបរិច្ឆេទ

(២)- កាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ

(៣)- ការដាក់ដិកល់លិខិតុបករណ៍ណាមួយនៃសេចក្តីប្រកាសមិនយល់ព្រមលើអនុសញ្ញានេះ រួមទាំងកាលបរិច្ឆេទដែលបានទទួល និង កាលបរិច្ឆេទដែលសេចក្តីប្រកាសមិនយល់ព្រមចាប់មានសុពលភាព ។

(៤)- ការទទួលនៃសេចក្តីប្រកាស ឬសេចក្តីជូនដំណឹងណាមួយដែលបានធ្វើឡើងស្របតាមអនុសញ្ញានេះ ។

ខ- បញ្ជូនឯកសារចំលងពិតដែលបានបញ្ជាក់ជាផ្លូវការនៃអនុសញ្ញានេះ ទៅអោយរដ្ឋទាំងអស់ដែលបានចុះហត្ថលេខា ឬ បានចូលជាសមាជិកនៃអនុសញ្ញានេះ ។

៣- នៅពេលដែលអនុសញ្ញានេះចូលជាធរមាន ឯកសារចំលងពិតដែលបានបញ្ជាក់ជាផ្លូវការនោះ ត្រូវបានបញ្ជូនដោយអ្នកថែរក្សាឯកសារទៅជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ សំរាប់ការចុះបញ្ជីនិងផ្សព្វផ្សាយ ដោយអនុលោម ទៅតាមមាត្រា១០២ នៃធម្មនុញ្ញសហប្រជាជាតិ ។

## មាត្រា ២២

អនុសញ្ញានេះ ត្រូវបានរៀបរៀងឡើងជាច្បាប់ដើមតែមួយ ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្បាញ ដែលអត្ថបទនីមួយៗមានតំលៃស្មើគ្នា ។

**ដើម្បីជាសាក្សីភាព** អ្នកដែលចុះហត្ថលេខាខាងក្រោម ត្រូវបានផ្តល់សិទ្ធិអោយដ៏ត្រឹមត្រូវ ដោយរដ្ឋាភិបាលរបស់ខ្លួនរៀងៗខ្លួនសំរាប់វត្ថុបំណងនោះ បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅទីក្រុងរ៉ូម ថ្ងៃទី ១០ ខែ មិនា ឆ្នាំ១៩៨៨ ។